# អភ័យឯកសិទ្ធិលើទ្រព្យសម្បត្តិ (immunity of property)

អភ័យឯកសិទ្ធិ (immunity) ជារបាំងមិនឲ្យវិនិច្ឆ័យសេចក្តីលើកម្មវត្ថុអ្វីមួយ។ អភ័យឯកសិទ្ធិនេះ ទាញចេញពីអធិបតេយ្យភាពការមិនជ្រៀតជ្រែកកិច្ចការងារផ្ទៃក្នុង (non-interference in domestic affair)។ វិធានអភ័យឯកសិទ្ធិរបស់រដ្ឋ ជាវិធានទំនៀមទម្លាប់អន្តរជាតិ។

ទ្រព្យសម្បត្តិ អាចត្រូវរឹបអូស ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ។ អភ័យឯកសិទ្ធិ លើទ្រព្យសម្បត្តិអាចត្រូវបដិសេធ (waiving) បានដោយតែរដ្ឋនៃទ្រព្យសម្បត្តិនោះ។ មានអនុសញ្ញាស្តីពី jurisdictional Immunity of State and their property ដែលអាចពាក់ព័ន្ធជាបញ្ហា នឹងការទាមទារសំណងដោយជនរងគ្រោះ។

បញ្ហានេះអាចកើតមានឡើង នៅពេលភាគីម្ខាងស្នើវិធានការបណ្តោះអាសន្ន បង្កកទ្រព្យរបស់ជនជាប់ចោទ។ បន្ថែមពីលើនេះ បញ្ហាអភ័យឯកសិទ្ធិលើទ្រព្យ ក៏កើតមាន ពេលអនុវត្តដីកាបង្កកទ្រព្យ នៅពេលទ្រព្យនោះនៅក្នុងដែភាគីទី៣ មានអភ័យឯកសិទ្ធិ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នឹងមិនអាចទទួលយកសំណើពាក់ព័ន្ធការ បង្កកទ្រព្យសម្បត្តិរបស់រដ្ឋ ដែលមិនមែនជាភាគីនៃលក្ខន្តិកៈរ៉ូមទេ ប្រសិនបើរដ្ឋ មិនបដិសេធនូវអភ័យឯកសិទ្ធិ( Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp.369-370)។